00452142

D349

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
10 / 02 / 2010
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានលម្អិតអំពីការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/កសចស |
| **ដាក់ទៅ** | : | ការិយាល័យសហចៅក្រមស៊ើបអង្កេត |
| **ភាគីអ្នកដាក់** | : | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| **ភាសាដើម** | : | អង់គ្លេស |
| **ថ្ងៃដាក់** | : | **ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០** |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.ចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើលើកទីប្រាំមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
**ពាក់ព័ន្ធនឹងបទចោទប្រល័យពូជសាសន៍មកលើជនជាតិខ្មែរ**

---

**អ្នកដាក់ឯកសារ៖**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

**អ្នកទទួលឯកសារ៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
11 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោកស្រី ស៊ិន ស៊ុវន

លោក David BLACKMAN

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី ចិត វណ្ណលី

លោក ពេជ អង្គ

លោកស្រី SilkeSTUDZINSKY

**ជំនួយការផ្នែកច្បាប់៖**

លោកស្រី Katrina GORDON

**សហមេធាវីការពារក្តីជនជាប់ចោទ:**

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

**នួន ជា**

លោក សុន អរុណ

លោក Michel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

**កាំង ហ្កេក អ៊ាវ ហៅ "ឌុច"**

លោក ការ សាវុត្ថ

លោក François ROUX

លោកស្រី Marie-Paule CANIZARES

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណី:**

លោក Olivier BAHOUGNE

លោកស្រី Lyma NGUYEN

លោក Mahdev MOHAN

D349



លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង**

## I. សេចក្តីផ្តើម និង សំណើ

១. យោងតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ជួសមុខឱ្យបណ្តាកូនក្តីរបស់ខ្លួនដែលជាប្រជាជនខ្មែរ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមដាក់សំណើសុំឱ្យមានកិច្ចស៊ើបសួរ ("សំណើ") ជូនសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") លើជនសង្ស័យឈ្មោះ នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និងកាំង ហ្គេកអ៊ាវ ហៅ ឌុច។

២. អង្គហេតុនានាដែលបានលើកឡើង នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ របស់ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") គាំទ្របទចោទដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1] និងរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាមនោះ ក៏អាចចាត់ទុកជាអង្គហេតុសម្រាប់គាំទ្របទចោទស្តីពីបទប្រល័យពូជសាសន៍មកលើផ្នែក ឬក្រុមជនជាតិខ្មែរផងដែរ។

៣. ថ្វីត្បិតតែការដាក់បញ្ចូលនូវអង្គហេតុដែលជាធាតុផ្សំនៃបទល្មើស គឺជាកិច្ចការប្រចាំថ្ងៃរបស់ចៅក្រមក៏ដោយ ក៏រយៈកាលក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥-១៩៧៩ (ដែលបង្កដោយបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដែលក្នុងនោះចុងចោទមានតួនាទីជាមេដឹកនាំជាន់ខ្ពស់) បង្កើតឱ្យមាននូវស្ថានភាពផ្លូវច្បាប់មិនច្បាស់លាស់មួយពាក់ព័ន្ធនឹងបទប្រល័យពូជសាសន៍។ ប.ក.ក បានអនុវត្តន៍គោលនយោបាយមួយ ក្នុងការ "*បោសសំអាត សម្រិតសម្រាំង និងបង្រួបបង្រួមក្រុមជាតិខ្មែរ*"[2]។ ប្រវត្តិវិទូ បានទទួលស្គាល់ថា ជាតិសាសន៍ខ្មែរប្រមាណ ៨០% គឺជា

---

1 ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ កថាខ័ណ្ឌ១២២ (គ) ដែលមានបញ្ជាក់ពីការប្រព្រឹត្តនូវសកម្មភាពជាច្រើន ដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ៖ "អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការនិរទេស ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការរំលោភ ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ ពូជសាសន៍ និងសាសនា មកលើអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ ពួកសក្តិភូមិ ពួកនាយទុន និងពួកគហបតី "ប្រជាជនថ្មី" "សមាសភាពមិនល្អ" ដែលគេសង្ស័យ ពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម [...]"។

2 Hurst Hannum, ច្បាប់អន្តរជាតិ និងអំពីប្រល័យពូជសាសន៍នៅកម្ពុជា: សម្លេងស្ងៀមស្ងាត់, អត្ថបទផ្សព្វផ្សាយអំពីសិទ្ធមនុស្សលើកទី១១ លេខ១ (ខែកុម្ភៈ ឆ្នាំ១៩៨៩) ទំព័រ៨២-១៣៨។ The John Hopkins University Press

ជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ ថាជារបបសាហាវយង់ឃ្នង។[3] យុត្តិសាស្ត្រជាតិ និងអន្តរជាតិ ច្បាប់យុត្តិសាស្ត្រ និងអង្គហេតុ ដែលថានិយមន័យនៃអំពើប្រល័យពូជសាសន៍ គឺជាប្រធានបទមួយដែលមានវិវាទដ៏ខ្លាំងក្នុងចំណោមក្រុមជនបញ្ញវន្ត[4] ក៏បង្ហាញនូវភាពមិនច្បាស់លាស់ផងដែរ។ ដូច្នេះហើយគោលបំណងនៃការដាក់សំណើនេះ គឺដើម្បីស្វែងរកនូវសេចក្ដីណែនាំរបស់អ្នកជំនាញ ដើម្បីផ្តល់នូវដំបូន្មានក្នុងការពិនិត្យពិច័យនូវអង្គហេតុដែលកំពុងត្រូវបានស៊ើបអង្កេតដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងកំណត់

---

១៩៨៩ ទំព័រ ៨៨-៨៩ “*ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ សម្រេចក្នុងការបោសសម្អាត សម្រិតសម្រាំង និងបង្រួបបង្រួមក្រុមជាតិសាសន៍ខ្មែរ - ការរំលឹកឡើងវិញដ៏មុតមាំនៃរបបណាហ្ស៊ី ក្នុងគោលបំណងសម្រិតសម្រាំង និងផ្សព្វផ្សាយនូវ “ជាតិសាសន៍ដើម”។ ដូចករណីរបបណាហ្ស៊ី សម្រេចក្នុងការសម្រិតសម្រាំងសង្គមដែលរីករាលដាលដល់ក្រុមជាតិសាសន៍ និងជាតិពន្ធ ដែលជាឧទាហរណ៍ បានបញ្ចូលនូវពួកសង្គមនិយម ពួករួមភេទដូចគ្នា ក៏ដូចគ្នានេះដែរកម្មវិធីសម្រិតសម្រាំងរបស់កម្ពុជាប្រជាធិបតេយ្យ បានរាលដាលដល់ការលុបបំបាត់ក្រុមជាតិពន្ធ និងសាសនា*”

3 Ciorciari, John D និង ឆាំង យុ បានប្រមូលឯកសារស្តីពីឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យ៖ ការនាំយកមកមេដឹកនាំខ្មែរក្រហមមកចំពោះមុខយុត្តិធម៌ Eds. Ramji, Jaya. Van Schaack, Beth Edwin Mellen Press (២០០៥) ទំព័រ២៦១។

4 ឧទាហរណ៍ Beth Van Schaack ក្នុង Mark Lattimer"s អំពើប្រល័យពូជសាសន៍ និងសិទ្ធមនុស្ស Ashgate (២០០៧) ជំពូក៥ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃនយោបាយកែតម្រូវចំនុចខ្មៅនៃអនុសញ្ញា ស្តីពី អំពើប្រល័យពូជសាសន៍ បានឱ្យយោបល់ថាមានច្បាប់កំពូលមួយ បានបកស្រាយថា៖ “*ការហាមឃាត់អំពើប្រល័យពូជសាសន៍តំណាងឱ្យគម្រូ jus cogens norm បទដ្ឋានទម្លាប់ និងផ្តាច់ការនៃច្បាប់អន្តរជាតិដែលមិនអនុញ្ញាតឱ្យប្រព្រឹត្តការប្រមាថមើលងាយ* ទំព័រ២២៦១ និង (ក្រោមទ្រឹស្តីច្បាប់សន្ធិសញ្ញាអន្តរជាតិ *Jus cogens norm* បង្គាប់នូវខ្លឹមសាររបស់សន្ធិសញ្ញា ពីព្រោះបទដ្ឋានទាំងនេះមិនអាច “ជ្រើសយកចេញ”) fn ១៤ ទំព័រ ២២៦១-២២៦២។ គាត់ក៏បានតវ៉ាយ៉ាងខ្លាំងដែរថា ក្រុមនយោបាយគួរកែតម្រូវបញ្ចូលទៅក្នុងអនុសញ្ញា ស្តីពី អំពើប្រល័យពូជសាសន៍។

បន្តទៀតថា តើចុងចោទបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើក្រុមតូចណាមួយ[5] ឬក៏ក្រុមដែលមានចំនួនច្រើនគួរសម[6]នៃជាតិខ្មែរ ឬក៏យ៉ាងណា។

៤. បទចោទដែលបញ្ជាក់អំពីអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ គឺកំណត់ចំពោះអំពើដែលសំដៅដោយផ្ទាល់ប្រឆាំងនឹងពុទ្ធសាសនិក ក្រុមជនជាតិចាម និងវៀតណាម[7] ហើយដែលត្រូវបានទទួលយកដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។[8] ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងអនុសញ្ញា ស្តីពីអំពើប្រល័យពូជសាសន៍ មិនតម្រូវថាក្រុមដែលត្រូវបានការពារ គឺជា ក្រុមជនភាគតិចមួយឡើយ។[9] បន្ថែមលើនេះទៀត នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ បានបង្ហាញនូវឯកសារយោងពាក់ព័ន្ធអង្គហេតុដ៏ច្រើនដែលបង្ហាញយ៉ាងច្បាស់ថា ចុងចោទអាចត្រូវបានចោទប្រកាន់ពីបទបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើជនជាតិខ្មែរ។ ដូច្នេះហើយ វិសាលភាពតូចចង្អៀតនៃបទចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ដែលស្នើឡើងដោយ សហព្រះរាជអាជ្ញា ដូចមានចែងនៅក្នុង ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ មិនបានរាំងខ្ទប់ការស៊ើបអង្កេតរបស់សហ

---

5 Thomas W Simon "*ច្បាប់ស្តីពីអំពើប្រល័យពូជសាសន៍*", Westport, Conn.: Praeger សន្តិសុខអន្តរជាតិ (២០០៧) ជំពូក៦៖ ជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍: Perpetrator Defined stated "*អំពើប្រល័យពូជសាសន៍មិនតម្រូវឱ្យមានការសម្លាប់ទាំងក្រុមនោះទេ។ ដូច្នេះ ក្រុមប្រល័យពូជសាសន៍ដែលត្រូវបានគេកំណត់មួយ អាចជាធាតុមួយរបស់ក្រុមធំ*" ត្រង់ទំព័រ១០៩។

6 រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstic*, IT-98-33-T, សាលក្រមថ្ងៃទី២ ខែសីហា ឆ្នាំ២០០១ "*ចេតនាចង់បំផ្លាញតែផ្នែករបស់ក្រុមក៏ដោយ ក៏ត្រូវមានការពាក់ព័ន្ធផងដែរ ទោះបីជា តាមរយៈតួលេខ ឬជាបរិមាណក្តី*" កថាខណ្ឌ ៦៣៤។

7 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២២ (ខ): ប្រល័យពូជសាសន៍ទៅលើពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម (ទំព័រ៣៧-៧២)។ ចំណុចនេះបង្កឱ្យមានការរំលោភបំពានទៅលើ អនុសញ្ញាទប់ស្កាត់ និងដាក់ទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ដែលត្រូវផ្តន្ទាទោសក្រោមមាត្រា៤, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

8 បទល្មើសថ្មីៗ ស្តីពីអំពើប្រល័យពូជសាសន៍មកលើប្រជាជនវៀតណាម និងប្រជាជនចាម ដកស្រង់ចេញមកពីកំណត់ហេតុ ចម្លើយរបស់ជនត្រូវចោទ នួន ជា D257 ERN: 00414545 - 0041455012 ធ្វើក្នុងខែធ្នូ ឆ្នាំ២០០៩ និងបទល្មើសផ្សេងៗទៀតរបស់ ខៀវ សំផន អៀង សារី អៀង ធីរិទ្ធ ដែលមាននៅក្នុងសំណុំរឿងក្តី។

9 ដូចឯកសារយោងខាងលើ ៣, Ciorciari, John D និង ឆាំង យុ ត្រង់ទំព័រ ២៦១។

ចៅក្រមស៊ើបអង្កេតទៅលើអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងនៅក្រោមយុត្តាធិការពេលវេលានិង យុត្តាធិការលើរូបបុគ្គលនៃតុលាការនេះឡើយ។

៥. សំណើសុំនេះ មិនមានគោលបំណងឱ្យមានការពង្រីកបន្ថែមនូវវិសាលភាពនៃនិយមន័យច្បាប់អំពីអំពើប្រល័យពូជសាសន៍ ដែលនៅស្ថិតក្រោមអនុសញ្ញា ស្តីអំពីអំពើប្រល័យពូជសាសន៍ និងក្រោមច្បាប់ អ.វ.ត.ក ឡើយ ប៉ុន្តែត្រូវតែអនុវត្តតាមទ្រឹស្តី "គ្មានបទល្មើស បើគ្មានច្បាប់ចែង" ដែលគោលការណ៍នេះធានាប្រាកដថាមានច្បាប់ដែលនៅជាធរមានមួយស្របពេលដែលមានការចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ គោលការណ៍នេះមិនបានច្រានចោលនូវច្បាប់ដូចគ្នានោះ ដែលអនុញ្ញាតឱ្យចៅក្រមធ្វើការបកស្រាយបាន ដោយសម្អាងលើអង្គហេតុ និងកាលៈទេសៈដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត។

"*ទោះបីជាបទបញ្ញត្តិច្បាប់មួយត្រូវបានព្រាងឡើងច្បាស់លាស់យ៉ាងណាក្តី ក៏បទបញ្ញត្តិមួយនោះគ្រប់ប្រព័ន្ធច្បាប់ទាំងអស់ រួមមានច្បាប់ព្រហ្មទណ្ឌផង ជៀសមិនផុតពីការបកស្រាយរបស់តុលាការឡើយ។ វាចាំបាច់តម្រូវឱ្យមានការបំភ្លឺនូវចំណុចសង្ស័យ ព្រមទាំងការសម្របទៅតាមការប្រែប្រួលផ្សេងៗនៃកាលៈទេសៈ។*"[10]

## II. បទដ្ឋានច្បាប់ដែលគ្រប់គ្រង

### *យុត្តាធិការលើកម្មវត្ថុនៃបណ្តឹង*

៦. អនុលោមតាមមាត្រា៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ទោសក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជា

---

[10] នីតិវិធី និងភស្តុតាង និងការអនុវត្តន៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅ Archbold Thomson Sweet & Maxwell London (ឆ្នាំ២០០៥) ជំពូក១៧, Defences and Procedural Bars to Jurisdiction, ដកស្រង់ចេញពីរឿងក្តី S.W. v. United Kingdom និង C.R. v United Kingdom ដែលបានដកស្រង់ចេញពីរឿងក្តី Streleyz [ប្រកបត្រឹមត្រូវ: Strelitz], Kessler និង Krenz v. Germany (ពាក្យសុំលេខ. 34044/96, 35532/97 និង 44801/មីនា 98, 22,2001, កថាខណ្ឌ ៥០)។ ទំព័រ៧៦១។

ប្រជាធិបតេយ្យ ("របបកាលកម្ពុជាប្រជាធិបតេយ្យ") ("កិច្ចព្រមព្រៀង") អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("អ.វ.ត.ក")មានយុត្តាធិការទៅលើកម្មវត្ថុនៃបណ្តឹងពាក់ព័ន្ធនឹង"បទឧក្រិដ្ឋប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការទប់ស្កាត់ និង ផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍")។[11]

៧. មាត្រា២ នៃអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ បានកំណត់អត្ថន័យប្រល័យពូជសាសន៍ជា "*អំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម* ដែលប្រព្រឹត្តឡើងក្នុងគោលបំណងដើម្បីបំផ្លាញ ទាំងស្រុង ឬមួយផ្នែក នៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាមួយ ដូចជា[12]៖

(ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

(ខ) ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរ ដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម

(គ) ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក។

(ឃ) ដាក់នូវវិធានការនានាក្នុងគោលបំណងរារាំង មិនឱ្យមានកំណើតទារកដល់សមាជិកនៃក្រុម

(ង) បញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត

៨. ដូចបានលើកឡើងពីខាងដើម ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ គឺសម្អាងលើអង្គហេតុដែលគាំទ្រដល់បទចោទ ដែលចុងចោទត្រូវបានចោទប្រកាន់ ថាបានប្រព្រឹត្តអំពើប្រឆាំងនឹងក្រុមជាតិខ្មែរមួយភាគធំ ឬចំណែកតូចមួយនៃភាគធំនោះ។ ការបែងចែកប្រភេទទាំងបីនៃភស្តុតាងប្រឆាំងនឹងមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា រួមមានដូចខាងក្រោម៖

---

[11] មាត្រា ៩ នៃកិច្ចព្រមព្រៀង

[12] វាជាការចាំបាច់ ដែលត្រូវកត់សម្គាល់ពីមាត្រា ៤(២) របស់ អ.វ.ត.ក ដែលបានកំណត់និយមន័យអំពើប្រល័យពូជសាសន៍ ដែលមានភាពខុសគ្នាបន្តិចបន្តួចពីខ្លឹមសារដែលមានចែងនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ដោយជំនួសដោយ "ជាដើម" និង "ដូចជា"។ ទោះបីជាភាពខុសគ្នានេះ អាចនឹងបង្កប់នូវបទដ្ឋានច្បាប់ខុសៗគ្នាក៏ដោយ ក៏សំណើនេះ ត្រូវផ្អែកលើនិយមន័យអំពើប្រល័យពូជសាសន៍ ដែលមានចែងនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ដូចដែលបានស្នើឡើងដោយកិច្ចព្រមព្រៀង និងច្បាប់របស់ អ.វ.ត.ក។

i. **អំពើ** ប្រសិទ្ធភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា (ភស្តុតាងដែលចំណុចចំនួនមួយ ឬពីរ ដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ *ត្រូវបានប្រព្រឹត្ត*)

ii. **ក្រុម** ក្រុមនានាដែលត្រូវចាត់ទុកថាជាគោលដៅនៃគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា (ដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើង មានគោលដៅសំដៅទៅលើសមាជិកមួយរូប ឬ*សមាជិក*ជាច្រើនរូប*នៃក្រុមដែលត្រូវបានការពារ* នៃក្រុមណាមួយក៏បាន៖ *ក្រុម ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា*)

iii. **គោលបំណង *ចេតនាពិសេស:*** សភាព និងទំហំនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា (ដែលអំពើត្រូវបានប្រព្រឹត្ត *ក្នុងចេតនាបំផ្លាញក្រុម* ទាំងស្រុង ឬផ្នែកណាមួយនៃក្រុមនោះ)។

## III. អំពើ

៩. មាត្រា២ នៃអនុសញ្ញាស្តីពីបទប្រល័យពូជសាសន៍ និងមាត្រា៤ នៃច្បាប់ អ.វ.ត.ក ចុងចោទត្រូវបានចោទប្រកាន់បានប្រព្រឹត្តបទល្មើសនានា ដែលមានចែងនៅក្នុងនិយមន័យអំពើប្រល័យពូជសាសន៍៖ (ក) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (ខ) ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម (គ) ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក។

១០. នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ មានចែងពីគោលនយោបាយនានា ដែលគាំទ្រទូទៅចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើក្រុមជាតិខ្មែរ ដែលចុងចោទត្រូវបានចោទប្រកាន់ថាបានអនុវត្តន៍ *"បណ្តាលឱ្យមានភាពអត់ឃ្លានមានលក្ខណៈទូលំទូលាយ អំពើសាហាវយង់*

00452151

D349



*ឃ្នងដែលមានលក្ខណៈជាប្រព័ន្ធ ស្ថានភាពរស់នៅដ៏អមនុស្សធម៌ និងការស្លាប់បាត់បង់ជីវិតប្រជាជន រវាងពី១,៧ ទៅ ២,២លាននាក់”* ។[13]

១១. ភស្តុតាងជាឯកសារ ការរៀបរាប់របស់សាក្សីជាមួយនឹងការដកស្រង់នានា ចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ភស្តុតាងនានាដែលចុងចោទត្រូវបានចោទប្រកាន់ថា មិនត្រឹមតែសម្លាប់មនុស្ស និងធ្វើឱ្យប្រជាជនខ្មែរទទួលរងនូវស្ថានភាពរស់នៅមួយ ដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែកដោយចេតនាប៉ុណ្ណោះនោះទេ ពួកគេនៅបានធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរ ដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកទៅលើប្រជាជនខ្មែរទៀតផង។[14]

១២.“បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការរើសអើងមានលក្ខណៈជាប្រព័ន្ធ ប្រឆាំងនឹងក្រុមដែលជាគោលដៅនានារួមទាំង៖ អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការស៊ីវិល អតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ ពួកសក្តិភូមិ ពួកមូលធន និងពួកគហបតី *ប្រជាជនថ្មី* ពុទ្ធសាសនិកជន ជនជាតិភាគតិចចាមនិងអ្នកកាន់សាសនាអ៊ីស្លាម ជនជាតិភាគតិចវៀតណាមនិងអ្នកកាន់សាសនាវៀតណាម *សមាសភាពមិនល្អដែលត្រូវបានគេសង្ស័យ”*។[15]

១៣.“បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការបែងចែករវាងប្រជាជន “ថ្មី” និងប្រជាជន “ចាស់” ឬប្រជាជន “មូលដ្ឋាន”។ ប្រជាជនថ្មី គឺអ្នកដែលបានជម្លៀសចេញពីទីក្រុង [បង្ខំឱ្យផ្លាស់ទី][16]

---

[13] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ២

[14] យោងតាមយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (“ICTR”) សាលាដំបូងតុលាការ ICTY បានទទួលស្គាល់ថា “ ការយល់ដឹងទូលំទូលាយមួយពីវាក្យស័ព្ទ ‘បំផ្លាញ’ ក៏មានការពាក់ព័ន្ធនឹង ‘បទល្មើសនានាដែលមិនអាចឈានដល់សេចក្តីស្លាប់ផងដែរ ដែលមានចែងនៅក្នុង *បណ្តឹងរដ្ឋអាជ្ញា ទល់នឹង* Blagojevic *និង* Jokic, IT-02-60-T, សាលក្រម ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ៦៦២។

[15] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ១២ (បញ្ជាក់បន្ថែម)

[16] នៅត្រង់នេះ ត្រូវប្រើប្រយោគ “បង្ខំឱ្យផ្លាស់ទី” ដែលមានអត្ថន័យត្រឹមត្រូវជាង “ជម្លៀសចេញ” ដោយសារតែប្រជាជនខ្មែរត្រូវបានខ្មែរក្រហមបង្ខំឱ្យចាកចេញពីទីក្រុង ដោយការប្រើលេសថា ប្រជាជនទាំងអស់ត្រូវជម្លៀសចេញពីទីក្រុង ដើម្បីសំណើលើកទីប្រាំមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរអំពីបទប្រល័យពូជសាសន៍

ចេញពីទីក្រុង ឬផ្នែកដទៃទៀតនៃប្រទេស ដែលកាលពីមុនមក ស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ប្រជាជន "ចាស់" ឬប្រជាជន "មូលដ្ឋាន" គឺជាប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលសាធារណរដ្ឋខ្មែរ។ តាមការយល់ឃើញរបស់ បក្សកុម្មុយនីស្តកម្ពុជា ទោះបីជា "ប្រជាជនថ្មី" ទាំងនោះមិនស្ថិតនៅក្នុងក្រុមដែលជាគោលដៅក្តី ក៏មានឆ្លងនូវអាកប្បកិរិយាបែប ពួកចក្រពត្តិ ពួកសក្តិភូមិ និងពួកនាយទុនដែរ ហើយបក្សកុម្មុយនីស្តកម្ពុជា បានជម្រុញយ៉ាងសកម្មនូវគំនិតដែលថា ប្រជាជន "ចាស់" ឬប្រជាជន "មូលដ្ឋាន" គឺប្រសើរជាងប្រជាជនថ្មី"។[17]

១៤." ប.ក.ក បានប្រតិបត្តិគោលនយោបាយនិងការត្រួតត្រារបស់ខ្លួនតាមរយៈបណ្តាញមន្ទីរឃុំឃាំង និងមន្ទីរសន្តិសុខទូទាំងប្រទេស ដែលបានឃុំឃាំង ធ្វើទុក្ខទោស ធ្វើទារុណកម្ម និងប្រហារជីវិតដោយខុសច្បាប់មកលើប្រជាជនកម្ពុជាយ៉ាងសន្ធឹកសន្ធាប់។ បទឧក្រិដ្ឋទាំងអស់នេះ គឺជាលទ្ធផលនៃការសម្រេចចិត្តដោយគិតគូរជាមុនដែលត្រូវបានរៀបចំផែនការនិងអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធដោយថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជានិងដែលជាផ្នែកមួយនៃការវាយប្រហារមានលក្ខណៈជាប្រព័ន្ធនិងទូលាយ មានទិសដៅប្រឆាំងនឹងប្រជាជនស៊ីវិលទាំងអស់"។[18]

## IV. ក្រុម

១៥. ប្រជាជនខ្មែរគឺជាក្រុមជាតិមួយក្រុម រីឯ "ប្រជាជនថ្មី" ដែលកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជានោះ គឺជាក្រុមគោលដៅមួយ ឬក្រុមមួយដែលជាធាតុរបស់ក្រុមជាតិនោះ និងជាក្រុមដែលត្រូវបានកំណត់ជាគោលដៅប្រល័យពូជសាសន៍ ដែលក្រុមដដែលនេះ អាចជាក្រុមធាតុ

---

ជៀសផុតពីការទម្លាក់គ្រាប់បែក ប៉ុន្តែជាក់ស្តែង វាគឺជាការអនុវត្តផែនការកសាងសង្គមឡើងវិញរបស់បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ។

[17] *ដូចជើងទំព័រមុន កថាខណ្ឌ១២(គ)*

[18] *ដូចជើងទំព័រមុន* កថាខណ្ឌ៣

មួយនៃក្រុមដ៏ធំមួយទៀតដោយកំណត់ទៅតាមខ្លឹមសាររបស់អនុសញ្ញា។[19] ការចាត់ថ្នាក់ប្រជាជនខ្មែរជាក្រុមជាតិមួយ មិនមែនជាបញ្ហាចម្រូងចម្រាសទេ។ ជាក់ស្តែង អ្នកជំនាញផ្នែកច្បាប់ជាច្រើនបានទទួលស្គាល់ថា ប្រជាជនខ្មែរគឺជាក្រុមជាតិមួយ ដោយកំណត់ទៅតាមខ្លឹមសារ ដែលមានចែងក្នុងអនុសញ្ញា។[20] គ្មានផ្នែកណាមួយនៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ដែលកំណត់ថា ក្រុមតម្រូវឱ្យមានការការពារ គឺត្រូវតែជាក្រុមភាគតិចនោះទេ។[21]

១៦. បន្ថែមលើនេះទៀត ទោះបីជាស្ថិតនៅក្នុងប្រវត្តិនៃសេចក្តីព្រាងរបស់អនុសញ្ញា ឬខ្លឹមសាររបស់អនុសញ្ញាផ្ទាល់ ក៏មិនមានបង្ហាញថានិយមន័យរបស់អំពើប្រល័យពូជសាសន៍ មិនរាប់បញ្ចូលករណីដែលជនរងគ្រោះគឺជាផ្នែកមួយរបស់ក្រុមចារីនោះដែរ។[22] ស្ថានការណ៍បែបនេះ គឺជា “ការប្រល័យពូជសាសន៍ឯង”។[23]

---

[19] ដូចឯកសារយោងខាងលើ ៥ Thomas W Simon, ត្រង់ទំព័រ ១០៩។

[20] S. Ratner, J. Abrams and J. Bischoff, Accountability for Human Rights Atrocities in International Law: Beyond the Nuremberg Legacy, Oxford University Press បោះពុម្ពផ្សាយលើកទី៣ (ឆ្នាំ២០០៩) ត្រង់ទំព័រ៣២១ ដែលបានដកស្រង់ពី Hurst Hannum និង David Hawke, The Case Against the Standing Committee of the Communist Part of Kampuchea, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៨៦ ទំព័រ១៤៧ - ៤៩ ដែលបានសរសេរថា៖: “ប្រជាជនខ្មែរពិតជារួមគ្នាជាជាតិសាសន៍មួយក្រុមកំណត់ទៅតាមខ្លឹមសាររបស់អនុសញ្ញាប្រាកដមែន”។ សូមមើលឯកសារយោងពីខាងលើ ២ ទំព័រ ១០៤ របស់ Hannum។ បន្ថែមលើនេះទៀត ក្រុមអ្នកជំនាញដែលត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានទទួលស្គាល់ផងដែរថា៖ “ប្រជាជនខ្មែរពិតជារួមគ្នាបង្កើតបានជាក្រុមជាតិសាសន៍មួយកំណត់ទៅតាមខ្លឹមសារអនុសញ្ញាប្រាកដមែន”។ របាយការណ៍របស់ក្រុមអ្នកជំនាញពីកម្ពុជា ដែលបានបង្កើតឡើងយោងតាមសេចក្តីសម្រេចរបស់អង្គមហាសន្និបាត 52/135, UN GAOR, សម័យប្រជុំលើកទី ៥៣ UN Doc. A/53/850, UN Doc. S/1999/231, កថាខណ្ឌ ៦៥ ក្នុងឧបសម្ព័ន្ធ (ឆ្នាំ១៩៩៩)។

[21] ដូចឯកសារយោងខាងលើ៣, Cioriari, John D. និង ឆាំង យុ ត្រង់ទំព័រ២៦១។

[22] John Quigley, អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍៖ ការវិភាគរបស់ច្បាប់អន្តរជាតិ Ashley (ឆ្នាំ២០០៦), ត្រង់ទំព័រ ១២៧ ដែលដកស្រង់ចេញពី អនុគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពី ការទប់ស្កាត់ការរើសអើងពូជសាសន៍ និងការការពារក្រុមជនភាគតិច, Ben Whithaker, បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពរបាយការណ៍ ស្តីពី សំណួរទាក់ទងនឹងការការពារ និងការដាក់ទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៨៥ (លទ្ធផលនៃការរកឃើញ៖ “និយមន័យមិនបានរួមបញ្ចូលករណីនានាដែលជនរងគ្រោះគឺជាជនដែលស្ថិតនៅក្នុងក្រុមតែមួយដូចគ្នានឹងពួកដែលបាន ប្រព្រឹត្តអំពើហឹង្សានោះដែរ។ ” ឯកសារអង្គការសហប្រជាជាតិលេខ E/CN/.4/Sub.2/1985/6, ទំព័រ១៦ សំណើលើកទីប្រាំមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរអំពីបទប្រល័យពូជសាសន៍

១៧. អនុសញ្ញា ស្តីអំពីអំពើប្រល័យពូជសាសន៍ ប្រហែលជាមិនមានបំណងដកចេញនូវអំពើទាំងនោះ ដែលប្រព្រឹត្តឡើងដោយពួកខ្មែរក្រហមទៅលើប្រជាជនខ្មែរ ថ្វីត្បិតតែវាប្រហែលជាមិនគិតអំពីកាលៈទេសៈតែមួយគត់នៃរបបខ្មែរក្រហមនៅពេលដែលគេធ្វើសេចក្តីព្រាងទាក់ទងនឹងអំពើឃោរឃៅនៃសង្គ្រាមលោកលើកទី២។ វាក្យស័ព្ទ "ក្រុមជាតិ" ដែលអនុម័តដោយអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ត្រូវបានឱ្យនិយមន័យថាជា "*បណ្តុំប្រជាជន ដែលត្រូវបានចាត់ទុកថា ចងភ្ជាប់ដោយចំណងផ្លូវច្បាប់ផ្អែកលើសញ្ជាតិរួមគ្នា រួមជាមួយនឹងការប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចទៅវិញទៅមក។*"[24]

---

ដែលអាចមើលបាននៅគេហទំព័រ: http://www.preventgenocide.org/prevent/UNdocs/whitaker/section2.htm) ដូចឯកសារយោង ខាងលើ ២ របស់ Hannum, ត្រង់ទំព័រ ១០៥។

[23] កំណត់សម្គាល់របស់អ្នករាយការណ៍របស់អង្គការសហប្រជាជាតិ, Abdelwahab Boudhiba, គណៈកម្មការសិទ្ធមនុស្ស អង្គប្រជុំលើកទី១៥១០ នីតិកាលទី៣៥ *សំណួរស្តីពីសិទ្ធមនុស្ស និងសិទ្ធជាមូលដ្ឋានគ្រប់តំបន់ក្នុងពិភពលោក* ទំព័រ៧ ឯកសារអង្គការសហប្រជាជាតិលេខ E/CN.4/SR.1510 (ឆ្នាំ១៩៧៩)។ សូមមើល Caroline Fournet, បទឧក្រិដ្ឋស្តីពីការបំផ្លិចបំផ្លាញ និងច្បាប់ប្រល័យពូជសាសន៍៖ ផលវិបាករបស់បទឧក្រិដ្ឋទាំងនោះទៅលើ Collective Memory, Ashgate (ឆ្នាំ២០០៧) ត្រង់ទំព័រ៤៩ ដែលបានថែងថា៖ "នៅក្នុងអនុសញ្ញាផ្ទាល់ ក៏បានថែងយ៉ាងច្បាស់ដែរពី ការការពារដល់ក្រុម "ជាតិ" ដោយរួមបញ្ចូលទាំង "ការប្រល័យពូជសាសន៍ឯង" ផងដែរ។" សូមមើលឯកសារយោងពីមុនលេខ២ របស់ Hannum ត្រង់ទំព័រ ១០៧ "គ្មានចំនុចណាមួយនៅក្នុង *travaux préparatoires* ដែលផ្ទុយ និងមិនស្របតាមការគាំទ្រដែលលើកឡើងថា ប្រជាជនខ្មែរនៃប្រទេសកម្ពុជា រួមគ្នាជាក្រុមជាតិដោយកំណត់តាមអត្ថន័យរបស់មាត្រា២ នោះទេ។"

[24] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jean-Paul Akayesu,* ICTR-96-4-T, សាលក្រមចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥១២។

D349



១៨. ជាងនេះទៅទៀត អង្គជំនុំជម្រះនៃតុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ចំពោះករណី *Akeyesu* បានយល់ឃើញថា គោលបំណងនៃអ្នកសរសេរសេចក្តីព្រាងអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ គឺដើម្បីការពារក្រុមដែល *អចិន្ត្រៃយ៍ និងប្រកបដោយស្ថិរភាព* ។[25]

១៩. វាមិនចាំបាច់ក្នុងការសន្និដ្ឋានថាចុងចោទមានបំណងបំផ្លាញដល់ក្រុមជាតិខ្មែរទាំងមូលនោះទេ។ ផ្ទុយទៅវិញ *"អំពើណាមួយដែលប្រព្រឹត្តឡើងក្នុងគោលបំណងដើម្បីបំផ្លាញផ្នែកណាមួយនៃក្រុម គឺជាអំពើមួយនៃអំពើប្រល័យពូជសាសន៍ដែលស្ថិតក្នុងអត្ថន័យនៃអនុសញ្ញា"* ។[26]

២០. នៅពេលផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០១ សាក្សី ហ៊ីម ហ៊ុយ បាននិយាយថា ចុងចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានបញ្ជាក់ថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនចំនួន ៤លាននាក់ ក្នុងចំណោមប្រជាជនដែលគេប៉ាន់ស្មានថាមានចំនួន៧លាននាក់ ត្រូវបានគេទុកឱ្យរួចពីសេចក្តីស្លាប់។[27]

---

[25] *ដូចដើងទំព័រមុន* ត្រង់កថាខណ្ឌ ៥១៦។ សាលាដំបូងយល់ឃើញថា វាមានសារៈសំខាន់ជាងគេ ដែលត្រូវគោរពតាមគោលបំណងរបស់អ្នកព្រាងពង្រាងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ដែលយោង *travaux préparatoires* ដែលមានគោលបំណងការពារក្រុមអចិន្ត្រៃយ៍ និងប្រកបដោយស្ថេរភាព។

[26] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Brdjanin*, IT-99-36-T, សាលក្រមចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៧០០។ សាលាដំបូងបន្តយល់ឃើញថា៖ "សាលាដំបូង យល់ស្របតាម *Krstic* និង *Stakic,* IT-97-24-T *"ចេតនា ចង់បំផ្លាញក្រុមមួយ ទោះបីជាដោយផ្នែកក៏ដោយ ក៏មានន័យថាចង់បំផ្លាញក្រុម ដែលផ្ទុយនឹងការរួបរួមរបស់បុគ្គលនានា ដែលស្ថិតនៅក្នុងក្រុមនោះ។"* កថាខណ្ឌ ៥២៤។

[27] *សំណុំរឿងក្តី កាំង ហ្កេកអ៊ាវ* លេខ 001-18-07-2007-ECCC/TC, ប្រតិចារឹកចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ត្រង់ទំព័រ៦១។ l. 14-17, ហ៊ីម ហ៊ុយ ត្រូវបានគេសួរនាំពីបទសម្ភាសន៍ដែលគាត់បានធ្វើឡើងនៅក្នុងឆ្នាំ១៩៩០៖ "នៅក្នុងមន្ទីរ ស-២១ ខ្ញុំបានឮ ឌុច និយាយឆ្លើយឆ្លងថា យើងត្រូវសម្លាប់ទាំងអស់ លើកលែងតែប្រជាជន ៤លាននាក់ទេ ដែលនេះ បានសេចក្តីថា ត្រូវសម្លាប់ប្រជាជនទាំងអស់។" ហ៊ីម ហ៊ុយ បានឆ្លើយថា៖ "ដំបូង ឌុចបានប្រាប់ថា—ត្រូវសម្លាប់ទាំងអស់ ដោយទុកតែ៤លាននាក់ប៉ុណ្ណោះ ប៉ុន្តែក្រោយមកគាត់និយាយថា ត្រូវកម្ទេចចោលទាំងអស់ ដែលខ្ញុំនៅចាំសម្តីនេះចាប់តាំងពីពេលនោះមក។" ជនជាប់ចោទមិនបានប្រកែកនឹងសក្ខីកម្មនេះទេ, T. ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ពីទំព័រ៦២ ១.២៣ ដល់ ទំព័រ៦៥ ១.១៥។

២១. *"ថ្វីត្បិតចារីនៃអំពើប្រល័យពូជសាសន៍ មិនមានគោលដៅបំផ្លាញក្រុមទាំងមូល ដែលបានទទួលការការពារដោយអនុសញ្ញាក៏ដោយ ពួកគេត្រូវតែចាត់ទុកថាជាផ្នែកនៃក្រុមដែល ពួកគេមានបំណងចង់បំផ្លាញក្រុមដែលជាក្រុមដោយឡែកមួយ ហើយដែលត្រូវតែបំបាត់ចោលបែបនេះ"* ។[28] ពាក្យ "បែបនេះ" ដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មានន័យថា ជនរងគ្រោះប្រាកដជាក្លាយជាក្រុមគោលដៅ *"ដោយសារខ្លួនជាសមាជិកនៃក្រុមដែលត្រូវបានការពារ"* ។[29]

២២. ប៉ុន្តែ *ប្រវត្តិនៃសេចក្តីព្រាង* នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រអន្តរជាតិ បង្ហាញថាតម្រូវការបែបនេះ រួមទាំងមូលហេតុផ្សេងៗទៀត មិនមែនជាលក្ខណៈពិសេសដូចគ្នាទេ។[30] យោងតាមរឿងក្តីករណី *រដ្ឋអាជ្ញា តទល់នឹង* *Blagojevic និង Jokic* របស់សាលាដំបូង ICTY ៖ *"ជនរងគ្រោះដោយសារបទឧក្រិដ្ឋ គឺត្រូវបានគេកំណត់មុខសញ្ញាដោយសារតែភាពជាសមាជិករបស់ខ្លួននៅក្នុងក្រុមដែលត្រូវបានការពារ ទោះបីជានេះមិនមែនជាកត្តាទោលចាំបាច់តែម្យ៉ាងក៏ដោយ"*។[31] ជាងនេះទៅទៀត សាលាឧទ្ធរណ៍ នៃ ICTY និង ICTR ក៏បានបញ្ជាក់ផងដែរ ពីភាពខុសគ្នារវាងមូលហេតុ និងចេតនាដែលសំខាន់នោះគឺ៖ *"មូលហេតុផ្ទាល់របស់ចារី ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺ ឧទាហរណ៍ ដើម្បីទទួលបាននូវប្រយោជន៍សេដ្ឋកិច្ចផ្ទាល់ខ្លួនឬប្រយោជន៍នយោបាយឬទម្រង់ខ្លះនៃអំណាច។ ការកើតមាននូវមូលហេតុផ្ទាល់ខ្លួន មិនរារាំងចារីមិនឱ្យមានបំណងជាក់លាក់ណាមួយ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ឡើយ"*។[32]

---

[28]ដូចឯកសារយោងខាងលើ ៦, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Radislav Krstic*, កថាខណ្ឌ ៥៩០។

[29] សូមមើលឯកសារយោងខាងលើ ២០, S. Ratner, J. Abrams និង J. Bischoff, ទំព័រ ២៨៦។ សូមមើលឯកសារយោងខាងលើ ២, Hannum, ទំព័រ ១០៧ - ១១០ ដែលយោង *travaux préparatoires* របស់អនុសញ្ញា។

[30] សូមមើលឯកសារយោងខាងលើ ២, Hannum ទំព័រ ១០៧។

[31] សូមមើលឯកសារយោងខាងលើ ៤, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojevic និង Jokic*, ត្រង់កថាខណ្ឌ ៦៦៩។

[32] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blaskic,* IT-95-14-A, សាលក្រមចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤។ កថាខណ្ឌ ៦៩៤ (យោងសាលដីកាសាលាឧទ្ធរណ៍ ICTY រឿងក្តី *Jelisic* និង *Kunarac* និងនៅ ICTR *Kayishema និង Ruzindana* "... សំណើលើកទីប្រាំមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរអំពីបទប្រល័យពូជសាសន៍

២៣. ក្រុមជាតិខ្មែរ ដែលកើតមានមុនឆ្នាំ១៩៧៥ទៀតនោះ មិនមានលក្ខណៈស្របគ្នាទៅនឹងគំនិតរបស់ចុងចោទដែលខ្លួនបានគិតចំពោះប្រទេសកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ នេះគឺជាភស្តុតាង ដែលបញ្ជាក់ពីភាពខុសគ្នារវាង ប្រជាជន "ថ្មី" និងប្រជាជន "ចាស់" ឬប្រជាជន "មូលដ្ឋាន" ដោយ ប.ក.ក ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បង្ហាញថា "បក្សបានជម្រុញយ៉ាងសកម្ម នូវគំនិតដែលថា ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន គឺប្រសើរជាងប្រជាជនថ្មី"។[33] នៅក្នុងការបែងចែកនេះ គឺបង្កប់នូវចេតនាដែលនឹងបំផ្លាញប្រជាជន "ថ្មី" ក្នុងចំនួនជាក់លាក់មួយរួចទៅហើយ។ ដូចពាក្យស្លោកខ្មែរក្រហមបានពោលថា៖ "*ទុកក៏មិនចំណេញ ដកចេញក៏មិនខាត!*"។[34]

២៤. ភាពចាំបាច់ក្នុងការបោសសម្អាតក្រុមជនជាតិខ្មែរ តាមរយៈការបំផ្លិចបំផ្លាញក្រុមនេះមួយផ្នែកត្រូវបានបញ្ជាក់ឱ្យយើងឃើញច្បាស់ថែមទៀតតាមរយៈការពិតដែលថា ប.ក.ក ពិតជាបានចាប់ខ្លួន និងប្រហារជីវិតប្រពន្ធកូនរបស់មនុស្សទាំងឡាយណាដែល ប.ក.ក សង្ស័យថាជាសមាសភាពមិនល្អ និងមនុស្សដែលខ្លួនចាត់ទុកថាជាខ្មាំង "អនុលោមតាមគោលនយោបាយ ប.ក.ក '...*ជីកស្មៅ ត្រូវជីកទាំងឫស*[35]'"។ ការពិតអស់ទាំងនេះ សបញ្ជាក់ថាចេតនាបំផ្លិចបំផ្លាញរបស់ ប.ក.ក ពុំមែនកំហិតត្រឹមតែទៅលើមនុស្សដែលខ្លួនចាត់ទុកថាជាសត្រូវរបស់របបខ្លួនតែប៉ុណ្ណោះទេ ប៉ុន្តែ ប.ក.ក ថែមទាំងមានចេតនាបំផ្លិចបំផ្លាញក្រុមជាតិខ្មែរដែល

---

*ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ជាទូទៅ មូលហេតុជម្រុញ គឺមិនមានការពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌឡើយ។'*

[33] សូមមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១២(គ)។

[34] Henri Locard, សៀវភៅតូចក្រហមរបស់ ប៉ុល ពត - ពាក្យស្លោករបស់ អង្គការ, Silkworm Books (ឆ្នាំ២០០៤) ការដកស្រង់ខ្លឹមសារពាក់ព័ន្ធនឹងប្រជាជនដែលមានជម្ងឺ ប៉ុន្តែគេបានកត់សម្គាល់នៅក្នុងរបបនោះថា "ប្រជាជនថ្មី" ត្រូវបានចាត់ទុកថាមានជម្ងឺ ហើយមានពាក្យស្លោកមួយទៀតដែលពោលថា "*ប្រជាជន១៧មេសា គឺជាជនបញ្ញើក្អែក*"ដែលបង្កប់អត្ថន័យថា ប្រជាជនថ្មីត្រូវតែតាមដានឱ្យជាប់ ហើយត្រូវកម្ទេចចោលនាពេលក្រោយ ទំព័រ ១៨៥ និង ទំព័រ ១៨៩។

[35] ដូចជើងទំព័រខាងលើ ត្រង់ទំព័រ៧៧ ដកស្រង់ចេញពី Ben Kiernan ក្នុង Pol Pot Regime: Race, Power and Genocide in Cambodia New Heaven: Yale University Press, (1996) ទំព័រ ២៨៨។

តំណាងឱ្យធាតុផ្សំទាំងឡាយទាំងពួងរបស់កម្ពុជា ដែលធ្លាប់មានអត្ថិភាពនៅមុនរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យទៀតផង។

២៥. លើសពីនេះ "សត្រូវ[36]" របស់ខ្មែរក្រហមគឺជាមនុស្សណាដែលខ្មែរក្រហមបានចាត់ទុកថាជាសមាជិករបស់ សេអ៊ីអា និងកាហ្សេបេ។ ការចាត់ទុកដូច្នេះវាពិតជាការធ្វើឡើងតាមអំពើចិត្ត ហើយក៏គ្មានការជាប់ពាក់ព័ន្ធទៅនឹងក្រុមបដិបក្ខដែលជាក្រុមសេដ្ឋកិច្ច សង្គម ឬនយោបាយណាមួយពិតប្រាកដឡើយ។ ការចោទតាមអំពើនេះត្រូវបានសបញ្ជាក់តាមរយៈការពិតដែលថាពាក្យ សេអ៊ីអា ដែលសាក្សីបានលើកឡើងនោះគឺពុំមែនចង់សំដៅលើ "សេអ៊ីអា" របស់ សហអាមេរិកទេ ប៉ុន្តែជា "សេអ៊ីអា[37]"របស់កម្ពុជាទៅវិញ។ ការចាត់ទុកមនុស្សថាជាខ្មាំងគឺគ្រាន់តែជាការប្រឌិតតែប៉ុណ្ណោះមិនខុសគ្នាប៉ុន្មានឡើយពីពាក្យថា "ជនក្បត់" "សមាសភាពមិនល្អ" "ប្រជាជន១៧មេសា" និង/ឬ "ប្រជាជនថ្មី" ហើយបំណងរបស់ពួកវាគឺត្រូវធ្វើតាមជំនឿរបស់ពួកវាដែលថាមនុស្សទាំងនោះគឺពិតជាខ្មាំងដែលត្រូវ "កម្ទេច"។ ដូច្នេះពាក្យថា "សត្រូវ" នេះ គ្មានមូលដ្ឋានការពិតត្រឹមត្រូវទេ ហើយនេះបង្ហាញឱ្យគេឃើញអំពីឧបាយកលមួយទៀតរបស់ ប.ក.ក ក្នុងការបំផ្លិចបំផ្លាញក្រុមជនជាតិខ្មែរមួយផ្នែក។

២៦. ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជន "ថ្មី" នេះ រឹងរឹតតែគាំទ្រសេចក្តីសំអាងដែលថាជនជាប់ចោទពិតជាមានចេតនាបំផ្លិចបំផ្លាញក្រុមជនជាតិខ្មែរមួយផ្នែកប្រាកដមែន។ ប្រជាជនខ្មែរពុំដែលធ្លាប់ចាត់ទុក ឬសម្គាល់ខ្លួនឯងថាជាប្រជាជន "ថ្មី" ឬប្រជាជន "មូលដ្ឋាន" នោះទេ ហើយការបែងចែកប្រភេទប្រជាជននេះទៀតសោត ក៏វាពុំត្រូវនឹងក្រុមដែលមានអត្តសញ្ញាណដែលពុំស្ថិតនៅក្រោមការគាំពាររបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍ផងដែរ។ ដីកាសន្និដ្ឋាន

---

[36] ដូចឯកសារយោងខាងលើ ២៧, T. ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៨៣,១.១, ជនជាប់ចោទបាននិយាយថា "ដូច្នេះ មនុស្សនេះ និងកូន ត្រូវបានចាត់ទុកថាជាខ្មាំង (បន្ថែមការគូសបញ្ជាក់) និង T. ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ៣២,១. ១៤-១៥, "ពួកគាត់ត្រូវបានចាត់ទុកថាជាខ្មាំង។ ដូច្នេះ ប្រពន្ធ និងកូនរបស់ពួកគាត់ក៏ត្រូវបានចាត់ទុកថា ជាខ្មាំងដែរ"។

[37] ដូចជើងទំព័រខាងលើ T. ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ១១,១, ២៤-២៥។ ជនជាប់ចោទ "...បង្កើតឡើងដោយគណៈកម្មាធិការមន្ទីរ ស-២១ ដើម្បីអនុវត្តគោលនយោបាយបក្ស នោះគឺត្រូវកម្ទេចសត្រូវ"។

បញ្ជូនរឿងឱ្យស៊ើបសួរទទួលស្គាល់ថា "ប្រជាជនថ្មី" មួយចំនួនពុំស្ថិតនៅក្នុង "ក្រុមផ្សេងៗដែលជាគោលដៅរបស់ខ្មែរក្រហម"មែន ប៉ុន្តែពួកគាត់បានរងការវាយប្រហារក៏ព្រោះតែមកពីពួកគាត់មានជំហរ "ចក្រពត្តិនិយម សក្តិភូមិនិយម និងមូលធននិយម"។ ការលាបពណ៌ប្រជាជនទាំងវង្វេងទិសនេះតំណាងឱ្យ *មូលហេតុជម្រុញ* នាំឱ្យមានការវាយប្រហារ ពុំមែនតំណាងឱ្យក្រុមសេដ្ឋកិច្ច នយោបាយ ឬសង្គមណាមួយពិតប្រាកដឡើយ។ ប.ក.ក មានបំណងកម្ចាត់របបចក្រពត្តិនិយម សក្តិភូមិនិយម និងមូលធននិយមឱ្យអស់ពីកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ ជនជាប់ចោទជឿថាខ្លួនចាំបាច់ត្រូវតែបំផ្លិចបំផ្លាញក្រុមជនជាតិខ្មែរមួយផ្នែក។

២៧. ដូច្នេះប្រសិនបើជនជាប់ចោទមានចេតនាបំផ្លិចបំផ្លាញក្រុមជាតិខ្មែរមួយផ្នែកមែននោះ *មូលហេតុជម្រុញ* ផ្សេងៗទៀតដែលនាំឱ្យជនជាប់ចោទធ្វើដូច្នោះកាលពីសម័យកម្ពុជាប្រជាធិបតេយ្យវាពុំពាក់ព័ន្ធឡើយ។

២៨. វាជាការចាំបាច់ដែលយើងត្រូវបញ្ជាក់ថា ប្រសិនបើការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនខ្មែរដែលមាននៅគ្រប់ទីកន្លែង វា "បណ្តាលមកពីអំពើហិង្សាដែលពុំបានគិតទុកជាមុន ឬស្ថានភាពយ៉ាប់យ៉ឺនដែលបានបង្កើតឡើងនៅក្នុងសង្គមជាទូទៅ" នោះគេនឹងពិបាកសន្និដ្ឋានណាស់ថាអំពើដែលប្រជាជនខ្មែរទទួលរង វាគឺជាអំពើប្រល័យពូជសាសន៍តាមអនុសញ្ញាអំពើប្រល័យពូជសាសន៍[38]។ ក៏ប៉ុន្តែការប្រហារជីវិតជាទ្រង់ទ្រាយធំ វាពុំមែនជាបញ្ហានៃអំពើហិង្សាដែលពុំបានគិតទុកជាមុនទេ។ ការប្រហារជីវិតត្រូវបានរៀបចំឡើងជាសម្ងាត់ដោយ ប.ក.ក។ ការស្លាប់បាត់បង់ជីវិតដោយសារភាពអត់ឃ្លាន និងការធ្វើការងារបាក់កម្លាំងក្នុងចំនួនរាប់សែននាក់នោះពុំមែនជាផលវិបាកដែលខ្មែរក្រហមពុំចង់បានតាមរយៈការបង្កើតឱ្យមានស្ថានភាពយ៉ាប់យ៉ឺននោះឡើយ។ ក៏ប៉ុន្តែផលវិបាកទាំងនេះគឺបណ្តាលមកពីគោលនយោបាយខ្មែរក្រហមដែលមានចេតនាបំផ្លិចបំផ្លាញប្រជាជនមួយផ្នែកដើម្បីបោសសម្អាតក្រុមជាតិខ្មែរនេះឯង[39]។ គេបានចោទថាជនជាប់ចោទកាលនោះបានបដិសេធពុំទទួលជំនួយបរទេស និងបានបង្កើតផែន

---

[38] មើលឯកសារយោងខាងលើ ២០ S. Ratner, J. Abrams and J. Bischoff ត្រង់កថាខណ្ឌ២៨៦-៨៧។

[39] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣។

ការផលិតកម្មហួសពីការផលិតបានជាក់ស្តែង ទើបបង្កើតឱ្យមានស្ថានភាពការងារដែលបានបណ្តាលឱ្យមនុស្សខ្មែររាប់សែននាក់ស្លាប់បាត់បង់ជីវិត[40]។

២៩. Hurst Hannum បានកត់សម្គាល់ឃើញថា ដើម្បីឱ្យស្របតាមគំនិតកសាងសង្គម ឬជាតិមួយថ្មី ហេតុផលគឺថាខ្មែរក្រហមមានតែចោទប្រជាជនខ្មែរថាក្បត់ប៉ុណ្ណោះ ពីព្រោះពួកវាគង់តែកម្ចាត់ប្រជាជនខ្មែរចោលដដែល[41]។ ពួកវាពុំត្រឹមតែចាត់ទុកប្រជាជនខ្មែរថាជាខ្មាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចាត់ទុកមនុស្សមិនស្មើនឹងសត្វផង[42]។ ក្នុងអំឡុងរយៈពេល៦ខែ ក្នុងឆ្នាំ ១៩៧៨ គិតជាអប្បបរមា ខ្មែរក្រហមបានប្រហារជីវិតមនុស្សអស់ចំនួនប្រមាណ ១០០.០០០ នាក់ នៅក្នុងការធ្វើវិសុទ្ធកម្មភូមិភាគបូព៌ា។ Hannum កត់សម្គាល់ឃើញដូចតទៅនេះ៖

*"ថ្វីបើមនុស្សមួយចំនួនដែលខ្មែរក្រហមបានប្រហារជីវិតនៅភូមិភាគបូព៌ា សុទ្ធតែជាមនុស្សស្ថិតនៅក្នុងក្រុមនយោបាយដែលគេស្គាល់ ហើយដែលត្រូវថ្នាក់ដឹកនាំមជ្ឈិមបក្សកម្ពុជាប្រជាធិបតេយ្យចាត់ទុកថាក្បត់ក្តី ក៏ប្រជាជនក្នុងចំនួនដ៏ច្រើនជាងនេះត្រូវបានខ្មែរក្រហមសម្លាប់ដែរ ក៏ព្រោះពួកវាចាត់ទុកប្រជាជនទាំងនោះថាជាមនុស្សពាក់ព័ន្ធដោយសារពួកគាត់ធ្លាប់បានរស់នៅក្រោមការក្តោបក្តាប់របស់ពួកក្បត់ [តាមការសន្មតរបស់ខ្មែរក្រហម][43]"*។

៣០. តាមរយៈឧទាហរណ៍ទាំងពីរខាងលើ បញ្ជាក់ថាប្រជាជនខ្មែរត្រូវបានខ្មែរក្រហមសម្លាប់ដោយសារមកពីពួកគាត់ជាសមាជិកនៃក្រុមជាតិខ្មែរ។ ប្រជាពលរដ្ឋកម្ពុជាស្ទើរគ្រប់រូបងាយនឹងទទួលរងគ្រោះពីការវាយប្រហាររបស់ខ្មែរក្រហម។ ការវាយប្រហារនេះជាផ្នែកមួយនៃ

---

[40] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ១១។

[41] មើលឯកសារយោងខាងលើ ២ Hannum ដកស្រង់ចេញពី Barnett, A Highly Centralized Dictatorship នៅ Chandler and Kiernan ចម្លើយរបស់ អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ដកស្រង់ នៅក្នុងឯកសាររបស់ Chandler ដែលមានចំណងជើងថា Perceptions of Cambodian History នៅក្នុងផ្នែកស្តីពី Revolution and its aftermath in Kampuchea: Eight Essays 34, D.P. Chandler & Ben Kiernan eds., (1983) ត្រង់ទំព័រ ២២៤ ដែលថា "...ខ្មែរក្រហមកម្ចាត់ប្រជាជនចោល ដោយសារពួកគាត់ត្រូវបាន ពួកវាដោយខុសថាជាជនក្បត់ ពីព្រោះពួកគាត់ត្រូវបានចោទពីបទក្បត់ ពីព្រោះពួកវានឹងកម្ចាត់ពួកគាត់ចោល"ទំព័រ៨៩។

[42] ដូចដើងទំព័រខាងលើ Hannum ត្រង់ទំព័រ ៨៩។

[43] ដូចដើងទំព័រខាងលើ Hannum ត្រង់ទំព័រ ៩០។

គោលនយោបាយបោសសម្អាតនិងកសាងកម្ពុជាឡើងវិញ។ ប្រជាពលរដ្ឋកម្ពុជាងាយនឹងទទួលរងគ្រោះ ពីការវាយប្រហាររបស់ ប.ក.ក ដោយសារពួកគាត់ជាសមាជិកនៃក្រុមជាតិខ្មែរ។

៣១. មតិដែលជំទាស់ទៅនឹងការកំណត់បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅកម្ពុជាក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យថាជាអំពើប្រល័យពូជសាសន៍លើកអំណះអំណាងថាទង្វើរបស់ខ្មែរក្រហមពុំទាន់បានបំពេញឱ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌចាំបាច់ស្តីពី *កម្រិតនៃចេតនា* នៅឡើយទេ[44]។ មតិទាំងនោះលើកឡើងថាខ្មែរក្រហមបានកំណត់គោលដៅទៅលើជនរងគ្រោះដែលពុំមែនជាជនជាតិភាគតិច ថាជាសមាសភាពសេដ្ឋកិច្ច នយោបាយ ឬសង្គមដែលត្រូវកម្ចាត់[45]។ ក្រុមទាំងនេះត្រូវបានទទួលការការពារតាមអនុសញ្ញាអំពើប្រល័យពូជសាសន៍[46]។

៣២. បើទោះបីជាយ៉ាងដូច្នេះក្តី ការអះអាងថាចេតនារបស់ខ្មែរក្រហមក្នុងការបំផ្លិចបំផ្លាញកំណត់ត្រឹមតែក្រុមសេដ្ឋកិច្ច សង្គមឬនយោបាយដែលជាក្រុមគេអាចកំណត់អត្តសញ្ញាណបាន

---

[44] ការបកស្រាយនេះបញ្ជាក់ថាដើម្បីបញ្ជាក់ថាជនជាប់ចោទមានចេតនាពិសេសចាំបាច់ គេត្រូវបង្ហាញថាខ្មែរក្រហម ពិតជាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជនខ្មែរ ពីព្រោះពួកគេមានចេតនាបំផ្លិចបំផ្លាញក្រុមជនជាតិ ខ្មែរមួយផ្នែក។ យោងតាមឯកសារយោងខាងលើ២ Hannum "*ទាក់ទិននឹងក្រុមជនជាតិខ្មែរ រដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យពិតជាពុំមានចេតនាបំផ្លិចបំផ្លាញក្រុមជនជាតិខ្មែរ* "*ទាំងស្រុង*" ពីព្រោះវាមានន័យថាជាបំផ្លាញក្រុមរបស់ពួកខ្លួនផ្ទាល់ដែរ។ ថ្វីបើដូច្នេះក្តី ក៏ពួកគេនៅមានចេតនាច្បាស់លាស់ក្នុងការបំផ្លិចបំផ្លាញក្រុមជនជាតិខ្មែរ "មួយផ្នែក" ត្រង់ទំព័រ១១១។

[45] William Schabas Universal Jurisdiction: Myths, Realities and Prospect: Problems of International Codification- Were the Atrocities in Cambodia and Kosovo Genocide? នៅ New England Law Review (2001) វ៉ុល ៣៥ (២) កថាខណ្ឌ២៩០។

[46] ដូចឯកសារយោងខាងលើ ២៤ ត្រង់កថាខណ្ឌ៥១១ ដែលនិយាយថា "ក្នុងពេលអាន *ឯកសារការងារត្រៀមរៀបចំ* នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ វាហាក់ដូចជាបង្ហាញថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានគេយល់ថាជាការកំណត់គោលដៅតែទៅលើក្រុម "អចិន្ត្រៃយ៍" ដែលត្រូវបានបង្កើតឡើងជាអចិន្ត្រៃយ៍ និងមនុស្សក្នុងក្រុមមានសមាជិកភាពតាំងពីកំណើត ដោយពុំរាប់បញ្ចូលក្រុម "ចល័ត" ដែលមនុស្សអាចចូលជាសមាជិកតាមរយៈការស្ម័គ្រចិត្តម្នាក់ៗដូចជាក្រុមនយោបាយ ឬសេដ្ឋកិច្ច"។

នោះ គឺជាការកំណត់អង្គហេតុខុសយ៉ាងធ្ងន់ធ្ងរ[47]។ ជាការច្បាស់ណាស់ថាវិនាសកម្មដែលខ្មែរក្រហមបានបង្កឡើង ពុំកំណត់ត្រឹមតែទៅលើក្រុមទាំងប៉ុន្មានខាងលើនេះទេ[48]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរគូសបញ្ជាក់ថា របបខ្មែរក្រហមមានចេតនាបំផ្លាញ ប្រជាជនខ្មែរមួយផ្នែកធំដែលជាក្រុមជាតិមួយ។

៣៣. សូម្បីតែក្រុមនានាដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានចាត់ទុកថាជាក្រុមដែល "ស្ថិតក្រោមគោលដៅ" ក៏ហាក់ដូចជាបង្ហាញឱ្យឃើញពីមូលហេតុជម្រុញនៃការរើសអើងជាជាងបង្ហាញអំពីក្រុមដែលគេអាចកំណត់អត្តសញ្ញាណបាន។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអះអាងថា "សមាសភាពមិនល្អ" ដែលខ្មែរក្រហមសង្ស័យ គឺជាក្រុមដែលរងការរើសអើងពីសំណាក់ប.ក.ក។ ប៉ុន្តែតាមការពិត សមាជិកក្រុមជាតិខ្មែរគ្រប់រូបគឺសុទ្ធសឹងតែអាចត្រូវខ្មែរក្រហម ចាត់ទុកថាជាមនុស្សសមាសភាពមិនល្អទាំងអស់។ ចម្លើយរបស់សាក្សីនានាបង្ហាញថាគេអាចចាត់ទុកនរណាម្នាក់ថាជាមនុស្ស "សមាសភាព មិនល្អ" ទៅតាមហេតុផលផ្សេងៗដូចជាការមានទំនាក់ទំនងស្នេហាជាមួយគ្នា ឬឈឺ "ពុត"[49]។

---

[47] ដូចឯកសារយោងខាងលើ ២ Hannum ត្រង់ទំព័រ ១១២-១១៣ ដែលគូសបញ្ជាក់ថា "[...] វាពុំស្របនឹងគោលបំណងពាក្យពេចន៍ ឬការងារត្រៀមរៀបចំនៃអនុសញ្ញា ដែលគ្រាន់តែដើម្បីកំណត់ ១ ភាគ៧ ទៅ ១ ភាគ៣ នៃចំនួន ប្រជាជន [របស់កម្ពុជា] ថាជាក្រុម "នយោបាយ" ដែលវាហួសពីវិសាលភាពនៃអនុសញ្ញា។

[48] ដូចឯកសារយោងខាងលើ២២ Quigley លើកអំណះអំណាងថា "...[A]brams ចាត់ទុកឧបសគ្គនៅក្នុងអង្គហេតុ នេះថាចារីជនជាតិខ្មែរបានផ្តោតទៅលើក្រុមជាក់លាក់នៅក្នុងក្រុមជនជាតិខ្មែរ ហើយក្រុមទាំងនោះពុំមាននិយាយនៅ ក្នុងមាត្រា II ឡើយ ដូចជា អ្នករដ្ឋការរបបមុន បញ្ញវន្ត និងសាស្ត្រាចារ្យ។ [លុបចោលជើងទំព័រ]។ ប៉ុន្តែ គេអាចមាន ចេតនាបំផ្លិចបំផ្លាញក្រុមមួយ តាមរយៈការបំផ្លិចបំផ្លាញក្រុមតូចណាមួយនៅក្នុងក្រុមនោះ។ ការដែលពុំមាននិយាយ ដល់ក្រុមទាំងនេះនៅក្នុងមាត្រាII ពុំបដិសេធអំពីចេតនាប្រល័យពូជសាសន៍ឡើយ។ គ្មានអ្វីនៅក្នុងមាត្រាII ឬក្នុងលក្ខខណ្ឌតម្រូវរបស់ខ្លួន ច្រានចោលការទទួលខុសត្រូវចំពោះអំពើប្រឆាំងនឹងក្រុមមួយដែលចារីជាសមាជិករបស់ក្រុមនោះឡើយ"។ ត្រង់ទំព័រ១២៩។

[49] ជាឧទាហរណ៍ សូមមើល របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចក្នុងអង្គភាព ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ឯកសារលេខ E3/144, ERN: 00143564-00143565 (EN)។

៣៤. ហេតុផលរាប់មិនអស់ក្នុងការសម្លាប់ និងធ្វើបាបធ្ងន់ធ្ងរខាងរូបរាងកាយរបស់ប្រជាជនខ្មែរនេះ ធ្វើឱ្យគេពុំអាចកំណត់ប្រភេទជនរងគ្រោះដែល ប.ក.ក មានចេតនាបំផ្លិចបំផ្លាញបានឡើយ ប៉ុន្តែអ្វីដែលយើងដឹងច្បាស់នោះ គឺថាជនរងគ្រោះគឺជាប្រជាជនខ្មែរមួយផ្នែក។

៣៥. ជាពិសេស ជនជាប់ចោទបានខិតខំបង្កើតសង្គមកម្ពុជាថ្មីសន្លាងមួយតាមរយៈការកសាងកម្ពុជាពី "ឆ្នាំសូន្យ" ហើយជនជាប់ចោទមានចេតនាជាក់លាក់ក្នុងការបំផ្លិចបំផ្លាញក្រុមជាតិខ្មែរមួយផ្នែកដែលពួកគាត់ពុំត្រូវការហើយចាត់ទុកថាបង្កការគំរាមកំហែងដល់ការអនុវត្តន៍គោលនយោបាយរបស់ ប.ក.ក។

## V. ចេតនា

៣៦. តាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ធាតុផ្សំផ្នែកស្មារតីចាំបាច់ដើម្បីកំណត់អំពើណាមួយថាជាឧក្រិដ្ឋប្រល័យពូជសាសន៍ គឺ "ចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនូវក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"។ លក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានយល់ថាជា *dolus specialis* ឬជា "ចេតនាពិសេស" ដែលវាជា "ចេតនាឧក្រិដ្ឋធ្ងន់ធ្ងរដែលប្រាកដជាមុនអត្ថិភាព បន្ថែមពីលើចេតនាឧក្រិដ្ឋ ដែលមានជាប់មកជាមួយបទល្មើសមូលដ្ឋាន[50]"។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានពន្យល់ថា "ការដែលថាចារីត្រឹមតែដឹងថាឧក្រិដ្ឋកម្មមូលដ្ឋាន នឹងនាំឱ្យក្រុមជនរងគ្រោះទទួលរងវិនាសកម្មនោះវា

---

[50] Antonio Cassese et al., លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖ បទអត្ថាធិប្បាយ Vol.1 (Oxford University Press (2002) ត្រង់ទំព័រ៣៣៨។ សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Stakic IT-97-24-T សាលក្រម ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ៥២០ ផ្នែកសំអាងហេតុ "អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្ម ពិសេសដែលផ្តោតទៅលើចេតនាពិសេស។ ជាការពិត ឧក្រិដ្ឋកម្មនេះត្រូវបានកំណត់ប្រភេទ និងញែកដាច់ពីគេដោយ ចេតនា "លើសលប់"។ អំពើដែលមាននៅក្នុងលក្ខន្តិកៈនេះត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ នៅពេលគេរកឃើញថាចារីពុំត្រឹមតែចង់ប្រព្រឹត្តអំពើទាំងនោះទេ ប៉ុន្តែថែមទាំងមានចេតនាបំផ្លិចបំផ្លាញក្រុមគោលដៅទាំងស្រុង ឬមួយផ្នែកដែលជាក្រុមពិសេស និងដោយឡែកពីគេ។ កម្រិតនៃចេតនានេះគឺជា ចេតនាពិសេស ឬ"ចេតនាជាក់លាក់" ដែលពាក្យទាំង២នេះអាចប្រើជំនួសគ្នាទៅវិញទៅមក"។

ពុំទាន់គ្រប់គ្រាន់ទេ។ ការបង្កឱ្យមានវិនាសកម្មទាំងស្រុង ឬមួយផ្នែកត្រូវតែជាគោលបំណងនៃឧក្រិដ្ឋកម្មជាមូលដ្ឋាន[51]"។

៣៧. Hannum គូសបញ្ជាក់អំពីភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងមូលហេតុជម្រុញ និងចេតនា ដោយយល់ឃើញថា៖

*"ការសម្លាប់រង្គាលដោយពុំរើសមុខទៅលើក្រុមគ្រួសារ ភូមិដ្ឋាន និងក្រុមតូចៗនៃប្រជាជនខ្មែរបង្ហាញថារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពុំមែនមានគោលដៅត្រឹមតែកម្ចាត់គូរ សត្រូវនយោបាយ ឬកែទម្រង់រចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចរបស់កម្ពុជាឡើយ ប៉ុន្តែការសម្លាប់នេះបញ្ជាក់ឱ្យឃើញអំពីការបង្កើតមនុស្សខ្មែរឡើងវិញក្នុងទ្រង់ទ្រាយធំទៅតាមការយល់ឃើញដែលបានគិតទុកជាមុន។ ជាការពិត ការសម្លាប់ក្នុងទ្រង់ទ្រាយធំទាំងនេះគឺជាផលវិបាកផ្ទាល់មួយនៃចេតនាដាក់លាក់របស់ ប.ក.ក ក្នុងការបោសសម្អាតក្រុមជាតិខ្មែរ។ ចេតនារបស់របបនេះក្នុងការបោសសម្អាតក្រុមជាតិខ្មែរ បញ្ជាក់ឱ្យឃើញនូវចេតនារបស់ពួកគេ ក្នុងការបំផ្លិចបំផ្លាញក្រុមនេះមួយផ្នែក[52]"។*

៣៨. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចនៅក្នុងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stakic ថាលក្ខខណ្ឌតម្រូវនៃចេតនា និង ចេតនាពិសេស អាចត្រូវបានសន្និដ្ឋានដូចខាងក្រោម៖ "ជាក់ស្តែងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការនេះ និងសាលាក្តីរ៉្វាន់ដា គេបានទទួលស្គាល់ជាទូទៅថាចេតនាពិសេសនៃអំពើប្រល័យពូជសាសន៍ អាចត្រូវបានគេទាញសន្និដ្ឋានតាមរយៈអង្គហេតុ កាលៈទេសៈជាក់ស្តែង ឬ "លំនាំនៃអំពើដែលមានគោលបំណងច្បាស់លាស់[53]"។

---

[51] ដូចឯកសារយោងខាងលើ ១៤ រដ្ឋអាជ្ញា ទល់នឹង Blagojevic and Jovic ត្រង់កថាខណ្ឌ៦៥៦។

[52] ដូចឯកសារយោងខាងលើ ២ Hannum ត្រង់ទំព័រ ៨៩។ គាត់និយាយសំដៅទៅលើរបាយការណ៍អង្គការលើកលែងទោសអន្តរជាតិ ដែលបានរកឃើញថាការកម្ចាត់មនុស្សដែលគេពុំត្រូវការ ត្រូវបានចាត់ទុកថា "មនុស្សគ្មានតម្លៃ" ដែលបានកើតមានឡើងនៅកម្ពុជានោះ ក្នុងនោះរួមមានការសម្លាប់រង្គាល់ក្រុមគ្រួសារជនរងគ្រោះទាំងមូល និងភូមិដ្ឋាន និងប្រជាជនជាច្រើនភាគរយទផតនៅក្នុងតំបន់ភូមិសាស្ត្រមួយចំនួន។

[53] ដូចឯកសារយោងខាងលើ ៥០ រដ្ឋអាជ្ញា ទល់នឹង Stakic កថាខណ្ឌ៥២៦។

ជាថ្មីម្តងទៀត ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstic* ៖

"ប្រសិនបើពុំមានភស្តុតាងជាក់ស្តែងបញ្ជាក់អំពីចេតនាប្រល័យពូជសាសន៍នោះទេ គេនៅតែអាចទាញសន្និដ្ឋានអំពីចេតនាពិសេសនេះបាន តាមរយៈកាលៈទេសៈអង្គហេតុនៃឧក្រិដ្ឋកម្ម[54]"។

៣៩. ក្នុងរឿងក្តី Krstic តុលាការ ICTY បានសម្រេចថាក្នុងចំណោមសញ្ញាសម្គាល់ផ្សេងៗចេតនាចាំបាច់សម្រាប់អំពើប្រល័យពូជសាសន៍ បានស្តែងឲ្យឃើញតាមរយៈការលាក់បំពួនសាកសពដែលនៅក្នុងរណ្តៅសាកសពរួមពេញទូទាំងប្រទេស និងការបដិសេធជាហូរហែមិនឲ្យមានការកប់សាកសពឲ្យបានសមរម្យ[55]។ កាលៈទេសៈអង្គហេតុជុំវិញការប្រហារជីវិតជាទ្រង់ទ្រាយធំតាមការបញ្ជារបស់ ប.ក.ក មានលក្ខណៈស្រដៀងៗគ្នា ដោយហេតុថារណ្តៅសាកសពរួមដែលគេពុំបានដឹង ត្រូវបានរកឃើញនៅពេញទូទាំងកម្ពុជាភ្លាមៗក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ។

៤០. ដូច្នេះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពុំចាំបាច់មានឯកសារនិយាយយោងដល់ភស្តុតាងដែលបង្ហាញចម្លើយច្បាស់លាស់ពីជនជាប់ចោទ ទាក់ទិននឹងចេតនារបស់ពួកគេក្នុងការបំផ្លិចបំផ្លាញក្រុមជាតិខ្មែរមួយផ្នែកឡើយ។ ក្រៅពីការស្លាប់ និងការធ្វើបាបអមនុស្សធម៌ជាបន្តបន្ទាប់ទៅលើក្រុមជាតិខ្មែរ គោលនយោបាយ ប.ក.ក គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់ថាជនជាប់ចោទគឺពិតជាមានចេតនាដែលជាលក្ខខណ្ឌតម្រូវប្រាកដមែន។

## VI. អ្នកជំនាញការ

[54] រដ្ឋអាជ្ញា ទល់នឹង Krstic IT-98-33-A ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ៣៤។

[55] ដូចឯកសារយោងខាងលើ ៦ រដ្ឋអាជ្ញា ទល់នឹង Krstic កថាខណ្ឌ៥៩៦ "... [មាន] សញ្ញាបញ្ជាក់យ៉ាងច្បាស់លាស់ អំពីចេតនាបំផ្លិចបំផ្លាញក្រុម ដូចជាតាមរយៈការលាក់បំពួនសាកសពដែលនៅក្នុងរណ្តៅសាកសពរួម...ដោយមិនឲ្យ មានការកប់សាកសពឲ្យបានសមរម្យទៅតាមទំនៀមទម្លាប់ប្រពៃណីសាសនា និងបណ្តាលឲ្យមានការប៉ះពាល់ផ្លូវចិត្ត ដល់អ្នកនៅរស់។ ភាគច្រើននៃជនរងគ្រោះពុំអស់ចិត្តឡើយ នៅពេលបងប្អូនរបស់ពួកគេពុំត្រូវបានបញ្ជាក់ឲ្យច្បាស់ថា ស្លាប់ឬរស់នោះ។

៤១. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមអះអាងដោយសេចក្ដីគោរពថាកាលៈទេសៈ និងការអនុវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យក្នុងសម័យនោះគឺមានលក្ខណៈផ្សេងពីគេ ជាពិសេសដោយយោងទៅតាមការសម្លាប់ជាទ្រង់ទ្រាយធំ នូវក្រុមជាតិខ្មែរមួយផ្នែកធំ។ ច្បាប់អន្តរជាតិពុំអាចប្រកែកពុំព្រមផ្ដល់សំណង ចំពោះឧក្រិដ្ឋកម្មសាហាវយង់ឃ្នងបែបនេះ ដោយពុំបានវិភាគឱ្យល្អិតល្អន់អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសឱ្យបានត្រឹមត្រូវដោយអ្នកជំនាញការច្បាប់ដែលមានបទពិសោធន៍ដើម្បីជួយដល់ ក.ស.ច.ស នៅក្នុងបញ្ហាក្ដៅគគុកនេះ។

៤២. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើឱ្យ ក.ស.ច.ស តែងតាំងអ្នកជំនាញផ្នែកច្បាប់មួយរូបដែលមានឯករាជ្យ និងគុណវុឌ្ឍិខ្ពស់ ដើម្បីផ្ដល់ជាមតិយោបល់ទៅលើបញ្ហានេះថាតើការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ទៅលើក្រុមជាតិខ្មែរ ដែលជាក្រុមគោលដៅមួយវាសមស្របទៅតាមកាលៈទេសៈដែរឬយ៉ាងណា។ នៅក្នុងដំណើរការជ្រើសរើសអ្នកជំនាញផ្នែកច្បាប់នេះសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើឱ្យធ្វើការពិគ្រោះជាមួយភាគីទាំងអស់ជាមុនសិន ។

## VII. សន្និដ្ឋាន និងសំណើសុំ

៤៣. ជនជាប់ចោទត្រូវបានចោទប្រកាន់ថាបានអនុវត្តផែនការដ៏តឹងរ៉ឹង ដើម្បីកសាងសង្គមកម្ពុជាពី "ឆ្នាំសូន្យ" ឡើងវិញ ហើយជនជាប់ចោទបានទទួលស្គាល់ថាដើម្បីធ្វើបែបនោះបាន ចាំបាច់ត្រូវតែបំផ្លាញក្រុមជាតិខ្មែរមួយផ្នែក។ ការអះអាងថាចេតនាបំផ្លិចបំផ្លាញរបស់ ប.ក.ក កំណត់តែចំពោះក្រុមនយោបាយ សេដ្ឋកិច្ច ឬសង្គមនោះ គឺជាការបកស្រាយអនុសញ្ញាអំពើប្រល័យពូជសាសន៍ក្នុងន័យទូទៅជ្រុល ហើយបង្កើតភាពស្រពេចស្រពិលអំពីភាពខុសគ្នារវាងចេតនាពិសេស និងមូលហេតុជម្រុញ។ ប្រសិនបើ ក.ស.ច.ស ជឿលើលទ្ធភាពដែលថាជនជាប់ចោទមានចេតនាបង្កឱ្យមានការស្លាប់បាត់បង់ជីវិតប្រជាជនខ្មែររាប់សែននាក់ តាមរយៈការអនុវត្តន៍គោលនយោបាយ ប.ក.ក ហើយទង្វើនេះអាចរាប់ថាជាអំពើប្រល័យពូជសាសន៍បាន ដូច្នេះតាមរយៈសំណើនេះ យើងល្មមទទួលយកមតិយោបល់ពីសំណាក់អ្នកជំនាញហើយ។

៤៤. សម្រាប់កូនក្តីរបស់យើងខ្ញុំ ដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីជនជាតិខ្មែរ ដែលពុំស្ថិតនៅក្នុងក្រុមជាតិពន្ធុណាមួយ វាជាការចាំបាច់ដែលគេត្រូវកំណត់ឱ្យបានត្រឹមត្រូវនូវប្រភេទឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តមកលើពួកគាត់ និងត្រូវដាក់បញ្ចូលការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ប្រសិនបើមាន។

ដូចដែលបានបញ្ជាក់ពីខាងលើ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើសុំឱ្យមាន៖

ការតែងតាំងអ្នកជំនាញការឯករាជ្យមានបទពិសោធន៍ និងគុណវុឌ្ឍិខ្ពស់ ដើម្បីពិនិត្យអង្គហេតុនៅក្នុងសំណុំរឿង និងដើម្បីបញ្ជាក់ថាតើការចោទជនជាប់ចោទពីបទប្រល័យពូជសាសន៍មកលើក្រុមជនជាតិខ្មែរ មានហេតុផលត្រឹមត្រូវដែរឬទេ។

សូមលោកចៅក្រមទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

| | |
|---|---|
| ហុង គីមសួន<br>សហមេធាវី | គង់ ពិសី<br>សហមេធាវី |
| យ៉ុង ផានិត<br>សហមេធាវី | ឡោ ជុនធី<br>សហមេធាវី |
| នី ចាន់ឌី<br>Silke Studzinsky<br>សហមេធាវី | ស៊ិន សុវ៉ន<br>David Blackman<br>សហមេធាវី |
| គីម ម៉េងឃី<br>សហមេធាវី | ម៉ុច សុវណ្ណារី<br>សហមេធាវី |
| Martine JACQUIN<br>សហមេធាវី | Philippe CANONE<br>សហមេធាវី |
| Elizabeth RABESANDRATANA<br>សហមេធាវី | Annie DELAHAIE<br>សហមេធាវី |
| Fabienne TRUSSES-NAPROUS | ជេត វណ្ណលី |
| ពេជ អង្គ | |

D349



សហមេធាវី

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១០។